ព្រឹត្តិបត្រ ស្តីពីបញ្ហា អាជីវកម្ម

កម្ពុជា

លេខ ១១

International Finance Corporation
World Bank Group

MEKONG PRIVATE SECTOR DEVELOPMENT FACILITY

# ការអនុវត្តដោយមិនសមស្របនូវមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត និងឥទ្ធិពលរបស់វាមកលើសេដ្ឋកិច្ចកម្ពុជា[១]



*ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាបច្ចុប្បន្ន មិនទាន់អាចចាត់ទុកថាមានប្រសិទ្ធិភាពគ្រប់គ្រាន់ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ចកាន់តែខ្លាំងទេ ។ ថ្វីបើការអនុម័តច្បាប់ថ្មីៗបន្ថែមទៀតជាការសំខាន់ ការអនុវត្តច្បាប់ដែលមានរួចហើយដោយយុត្តិធម៌ និងសមស្របក៏ជាការសំខាន់ដូចគ្នាដែរ ព្រោះថាការដែលអនុវត្តច្បាប់ដែលមានរួចហើយមិនបានត្រឹមត្រូវ និងមិនយុត្តិធម៌អាចជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាទាំងមូល ។*

*ឧទាហរណ៍ជាក់ស្តែងមួយគឺ សហគមន៍អាជីវកម្មនៅប្រទេសកម្ពុជាបារម្ភពីការអនុវត្តមាត្រាទី ៤៦ ស្តីអំពីការរំលោភលើសេចក្តីទុកចិត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលជាច្រើនឆ្នាំមកហើយ ។ ការអនុវត្តមាត្រាស្តីពីការរំលោភ លើសេចក្តីទុកចិត្តមិនត្រឹមត្រូវ ប្រើចំពោះករណីរំលោភលើកិច្ចសន្យា ធ្វើឱ្យសហគមន៍អាជីវកម្មខាតបង់ដោយផ្ទាល់រាប់ពាន់ដុល្លារ ហើយសេដ្ឋកិច្ចកម្ពុជាខាតបង់រាប់លានដុល្លារ និងបាត់បង់ការងាររាប់ពាន់ ដោយសារវិនិយោគិនលះបង់ឱកាសវិនិយោគ ។ សហគមន៍អាជីវកម្មក្នុងប្រទេសកម្ពុជា បានលើកបញ្ហានេះឡើងឱ្យរដ្ឋាភិបាលបានដឹង ។ ដើម្បីឆ្លើយតបនឹងការបារម្ភនេះ ក្នុងពេលថ្មីៗនេះរដ្ឋាភិបាលបានបង្កើតអនុគណៈកម្មាធិការពិសេសមួយនៃវេទិការផ្នែកឯកជន របស់រដ្ឋាភិបាលដើម្បីធ្វើការសិក្សាអំពីឥទ្ធិពលសេដ្ឋកិច្ចនៃការអនុវត្តមាត្រានេះដោយមិនត្រឹមត្រូវ ។ រដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ការសិក្សានេះ ដើម្បីដោះស្រាយបញ្ហាបំពានលើមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្តនេះ ហើយបង្កើនទំនុកចិត្តអ្នកវិនិយោគ ក្នុងបំណងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិទាំមូល ។*

*ព្រឹត្តិប័ត្រស្តីពីបញ្ហាអាជីវកម្មលេខនេះ នឹងពន្យល់ថាអ្វីទៅជាការរំលោភលើសេចក្តីទុកចិត្តការអនុវត្តជាក់ស្តែងក្នុងប្រទេសកម្ពុជា និងពិនិត្យមើលឥទ្ធិពលរបស់ការអនុវត្តមាត្រានេះទៅលើសេដ្ឋកិច្ចកម្ពុជា ។ ព្រឹត្តិប័ត្រនេះ ក៏សង្ខេបផងដែរពីគំហើញសំខាន់ៗនៃការសិក្សារបស់គណៈកម្មការពិសេសស្តីអំពី "រឿងក្តីដែលគេចោទប្រកាន់ដោយបំពានពីបទល្មើសរំលោភលើសេចក្តីទុកចិត្ត និងឥទ្ធិពលរបស់វាលើសេដ្ឋកិច្ចកម្ពុជា ។"[២]*

## តើការរំលោភលើសេចក្តីទុកចិត្តជាអ្វី?

ការរំលោភលើសេចក្តីទុកចិត្ត ជាបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងការលួចទ្រព្យសម្បត្តិ ដែលកើតឡើងក្នុងពេលដែល ជនជាប់ចោទបានទទួលទ្រព្យសម្បត្តិនោះស្របច្បាប់តាមរយៈកិច្ចសន្យាជាមួយម្ចាស់ទ្រព្យសម្បត្តិ ហើយជនជាប់ចោទ នោះបានតែបន្លំយកទ្រព្យសម្បត្តិនោះជាអចិន្ត្រៃយ៍ដោយចេតនា ។ កិច្ចព្រមព្រៀងរវាងម្ចាស់ទ្រព្យសម្បត្តិ និងជនជាប់ចោទអាចជាលាយល័ក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ឧទាហរណ៍ លោក **ក** បានខ្ចីម៉ូតូពីមិត្តរបស់គាត់ដែលជា លោក **ខ** នៅពេលព្រឹក ហើយលោក **ក** សន្យាថានឹងប្រគល់ម៉ូតូឱ្យទៅលោក **ខ** វិញ នៅពេលល្ងាច ។ ប៉ុន្តែ លោក **ក** មិនបាន ប្រគល់ម៉ូតូឱ្យទៅលោក **ខ** វិញទេ គាត់បែរជាលក់ម៉ូតូនេះឱ្យទៅលោក **គ** ។ ក្នុងករណីនេះ លោក **ក** បានប្រព្រឹត្តបទល្មើសរំលោភលើសេចក្តីទុកចិត្ត ។

---

[១] ដរាបណាគ្មានការសំគាល់ផ្សេងទៀតទេ ពតិមាននៅក្នុងព្រឹត្តិប័ត្រនេះ រួមទាំងស្ថិតិ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ទាំងឡាយ សុទ្ធតែដកស្រង់ចេញពីរបាយការណ៍ *"ស្តីអំពីរឿងក្តីដែលត្រូវបានចោទប្រកាន់ដោយបំពានពីបទល្មើសព្រហ្មទណ្ឌរំលោភលើសេចក្តីទុកចិត្ត និងឥទ្ធិពលរបស់វាទៅលើសេដ្ឋកិច្ចកម្ពុជា"* ដែលធ្វើឡើងដោយ អនុគណៈកម្មាធិការពិសេសមួយនៃវេទិការផ្នែកឯកជនរបស់រដ្ឋាភិបាល ក្រោមការឧបត្ថម្ភរបស់កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ ២០០៦

[២] ការសិក្សារនេះបានទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពី កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។ ដោសារការរំលោភ លើសេចក្តីទុកចិត្តជាបញ្ហារសើប ទើបមានតែមនុស្សប្រហែលជាង ១០ នាក់ប៉ុណ្ណោះដែលផ្តល់ពតិមានសំរាប់ការសិក្សារនេះ ។ ដូច្នេះ គំហើញនេះអាចមិនតំណាងឱ្យស្ថានភាពនៃប្រទេសកម្ពុជាទាំងមូលទេ ។ សំរាប់ពិតមានលំអិត សូមមើលរបាយការណ៍បោះពុម្ពផ្សាយខាងលើ ។

---

MEKONG PRIVATE SECTOR DEVELOPMENT FACILITY

**ព្រឹត្តិបត្រស្តីពីបញ្ហាអាជីវកម្ម** ផ្តល់ជូនលោកអ្នកដែលមានចំណាប់អារម្មណ៍ពីរឿងរ៉ាវទាក់ទិននឹងកិច្ចការអាជីវកម្មនូវសេចក្តីសង្ខេបខ្លីៗ និងសេចក្តីវិភាគលើប្រធានបទដែលពាក់ពន្ធ័នឹងបរិយាកាសអាជីវកម្មនៅកម្ពុជា ។ ព្រឹត្តិបត្រ័នេះមានរួមបញ្ចូលទាំងមតិ និងយោបល់ផ្សេងៗ របស់មជ្ឈដ្ឋានពាក់ពន្ធ័ផងដែរ ។

ព្រឹត្តិបត្រ័នេះ ត្រូវបានបោះពុម្ពឡើងដោយមានការឧបតម្ភពីសំណាក់អង្គការកម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាស្ថាប័នពហុជំនួយគ្រប់គ្រងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកឯកជននៃក្រុមធនាគារពិភពលោក ។

មតិ ឬយោបល់ទាំងឡាយដែលចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនតំណាងឱ្យទស្សនៈជាផ្លូវការ របស់អង្គការកម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ ឬ IFC ទេ វាគ្រាន់តែផ្តល់ជាព័តិមានយោងបន្ថែមតែប៉ុណ្ណោះ ។

តាមរយៈឧទាហរណ៍ខាងលើ គេទាមទារធាតុផ្សំសំខាន់ពីរដើម្បីឱ្យគេអាច កំណត់ជំលោះមួយថាជាការរំលោភលើសេចក្តីទុកចិត្តពោលគឺ **ធាតុផ្សំសំភារៈ និងធាតុផ្សំខាងផ្លូវសតិ** ។ ធាតុផ្សំសំភារៈគឺការកែបន្លំ ឬប្រើប្រាស់ទ្រព្យសម្បត្តិផ្ទុយពីអត្ថប្រយោជន៍របស់ម្ចាស់ទ្រព្យសម្បត្តិ ។ ធាតុផ្សំខាងសតិគឺជាចេតនាប្រព្រឹត្តបទល្មើសកែបន្លំ ឬប្រើប្រាស់ ទ្រព្យសម្បត្តិផ្ទុយពីប្រយោជន៍របស់ម្ចាស់ទ្រព្យសម្បត្តិ ។

**ធាតុផ្សំសំភារៈ**នៃបទល្មើសព្រហ្មទណ្ឌរំលោភលើសេចក្តីទុកចិត្តមានបីសំខាន់ៗ :

*១. ទ្រព្យសម្បត្តិត្រូវតែបានគេទុកចិត្តប្រគល់ទៅឱ្យជនជាប់ចោទទទួលឥតខុសត្រូវ* : ម្ចាស់ទ្រព្យសម្បត្តិត្រូវតែបាន ទុកចិត្តប្រគល់ទ្រព្យសម្បត្តិទៅឱ្យជនជាប់ចោទទទួលខុសត្រូវដោយស្របច្បាប់ ឧទាហរណ៍ដូចជា ការឱ្យប្រាក់ខ្ចី ការផ្ញើរប្រាក់ ឬការបញ្ចាំក្នុងកិច្ចសន្យាណាមួយ ។ បើជនជាប់ចោទទទួលបានទ្រព្យសម្បត្តិពីម្ចាស់ដោយខុសច្បាប់ ដូចជាការលួច ឬ ប្លន់ នោះគេមិនរាប់ចូលក្នុងបទល្មើសរំលោភលើសេចក្តីទុកចិត្តទេ ។

*២. ជនជាប់ចោទត្រូវតែបានសន្យាថានឹងសង ទ្រព្យសម្បត្តិនោះទៅឱ្យម្ចាស់ដើមវិញ ឬមួយប្រើប្រាស់វាតាមគោលបំណងកំណត់មួយៈ* បើម្ចាស់ទ្រព្យលក់ទ្រព្យសម្បត្តិ ឬឱ្យវាទៅជនជាប់ចោទ នោះការរំលោភលើសេចក្តីទុកចិត្តមិនអាចកើតមានឡើងបានទេ ។ វាអាចកើតមានឡើងតែក្នុងករណីដែលគេទុកចិត្តប្រគល់ទ្រព្យសម្បត្តិទៅឱ្យជនជាប់ចោទ ហើយជនជាប់ចោទបានសន្យាថានឹងប្រើប្រាស់ទ្រព្យសម្បត្តិនោះក្នុងគោលបំណងជាក់លាក់ណាមួយ ។ មាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្តមានបំណងរារាំងមិនឱ្យជនជាប់ចោទរក្សារទុកទ្រព្យសម្បត្តិសំរាប់ខ្លួនឯង ឬមិនឱ្យជនជាប់ចោទប្រើប្រាស់វាខុសពីគោលបំណងដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។ ឧទាហរណ៍ បើម្ចាស់ទ្រព្យសម្បត្តិ ឱ្យជនជាប់ចោទខ្ចីទ្រព្យសម្បត្តិអ្វីមួយ ហើយជនជាប់ចោទព្រមខ្ចី នោះមានន័យថាជនជាប់ចោទសន្យាថានឹងប្រគល់ទ្រព្យសម្បត្តិនោះទៅឱ្យម្ចាស់វិញ ។

*៣. ជនជាប់ចោទត្រូវតែបានចាត់ចែងការ ឬកែបន្លំលើទ្រព្យសម្បត្តិ:* ការកែបន្លំកើតឡើង នៅពេលដែលម្ចាស់ទ្រព្យសម្បត្តិមិនអាចទទួលទ្រព្យសម្បត្តិវិញបានជារៀងរហូត ។ ឧទាហរណ៍ជាទូទៅនៃការកែបន្លំ គឺការបំផ្លាញទ្រព្យសម្បត្តិនោះ លក់ទ្រព្យសម្បត្តិនោះទៅឱ្យភាគីទីបី ឬរក្សាទុកទ្រព្យសម្បត្តិដោយមិនព្រមប្រគល់ឱ្យទៅម្ចាស់វិញ ។

ធាតុផ្សំសំខាន់បំផុតនៃបទល្មើសរំលោភលើសេចក្តីទុកចិត្ត គឺ**ធាតុផ្សំខាងផ្លូវសតិ** ។ បើគ្មានចេតនាប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌទេ ជនជាប់ចោទមិនមានទោសពីបទរំលោភលើសេចក្តីទុកចិត្តទេ ទោះបីជាជននោះបានប្រព្រឹត្តធាតុផ្សំសំភារៈក៏ដោយ ។ ឧទាហរណ៍ **ម៉ូនីន**ខ្ចីលុយ ៥០០ ដុល្លារ ពីអ្នកជិតខាងរបស់គាត់ដើម្បីដាំពោត ។ គាត់សន្យាថានឹងសងលុយនេះទៅ អ្នកជិតខាងគាត់វិញ ៦ ខែក្រោយមក ។ ប៉ុន្តែដោយសារគ្រោះរាំងស្ងួត ដើមពោតរបស់គាត់ខូចខាតទាំងអស់ ។ ដូច្នេះ គាត់មិនអាចសងលុយទៅអ្នកជិតខាងរបស់គាត់វិញទេ ។ ក្នុងករណីនេះ គាត់មិនអាចបំពេញកាតព្វកិច្ចកិច្ចសន្យារបស់គាត់ ដែលតំរូវឱ្យគាត់សងបំណុលក្នុងរយៈពេល ៦ ខែទេ ។ ប៉ុន្តែ គាត់មិនបានប្រព្រឹត្តបទល្មើសរំលោភលើសេចក្តីទុកចិត្តទេ ព្រោះគាត់គ្មានចេតនាមិនសងលុយនោះឡើយ ។

ផ្ទុយទៅវិញ ក្នុងឧទាហរណ៍មួយទៀត បុគ្គលម្នាក់ដែលខ្ចីម៉ូតូពីអ្នកជិតខាងរបស់គាត់យកទៅប្រើប្រាស់មួយថ្ងៃ ហើយបែរជាលក់ម៉ូតូនោះទៅជនទីបីវិញ បុគ្គលនេះពិតជាបានប្រព្រឹត្តធាតុផ្សំខាងផ្លូវសតិ ។ គាត់មានចេតនារំលោភការសន្យារបស់គាត់ ដោយមិនប្រគល់ម៉ូតូឱ្យទៅម្ចាស់ដើមវិញ ហើយបែរជាលក់ម៉ូតូនោះឱ្យទៅបុគ្គលម្នាក់ទៀត ។ នេះជាការប្រព្រឹត្តខុសដោយចេតនា ដែលជាភស្តុតាងនៃចេតនាព្រហ្មទណ្ឌ ។ ជាលទ្ធផលគាត់បានប្រព្រឹត្ត បទល្មើសរំលោភលើសេចក្តីទុកចិត្ត ។

## ភាពខុសគ្នារវាង ការរំលោភលើសេចក្តីទុកចិត្ត និងការរំលោភលើកិច្ចសន្យា

គោលគំនិតនៃការរំលោភលើសេចក្តីទុកចិត្ត ដូចដែលបានបង្ហាញខាងលើ ជួនកាលអាចធ្វើឱ្យគេច្រលំគ្នានិងគោលគំនិតនៃការរំលោភលើកិច្ចសន្យា ។ ឧទាហរណ៍ **បុប្ផា** សន្យានឹងលក់អាវសូត្រ (មានការព្រមព្រៀងលើសាច់ក្រណាត) ទៅឱ្យ **រតនា** ក្នុងតំលៃ ៥០ ដុល្លារ ។ ពេលដែល**បុប្ផា** គ្រល់អាវសូត្រដូចដែលបានសន្យាទៅឱ្យ **រតនា** គាត់បែរជាមិនព្រមបង់ប្រាក់តាមការសន្យា ដោយនិយាយថាគាត់មិនត្រូវការអាវសូត្រនោះទៀតទេ ។ គេចាត់ទុករឿងនេះថាជាការរំលោភលើកិច្ចសន្យា ។

ការរំលោភលើកិច្ចសន្យា និងការរំលោភលើសេចក្តីទុកចិត្តមានចំណុចខុសគ្នាពីរ ។ ***ទីមួយ*** ការរំលោភលើ សេចក្តីទុកចិត្តទាមទារឱ្យមាន "ការទុកចិត្តប្រគល់ទ្រព្យសម្បត្តិទៅឱ្យជនជាប់ចោទដោយស្របច្បាប់" ។ កិច្ចសន្យាភាគច្រើន មិនមានការទុកចិត្តប្រគល់ទ្រព្យសម្បត្តិទៅឱ្យភាគីមួយដោយស្របច្បាប់ទេ ។ ក្នុងឧទាហរណ៍ខាងលើ **បុប្ផា**មិនបានទុកចិត្តប្រគល់ទ្រព្យសម្បត្តិទៅឱ្យ **រតនា**ទេ ។ ដូច្នេះ ប្រតិបត្តិការណ៍នេះមិនអាចចាត់ទុកជាការរំលោភលើសេចក្តីទុកចិត្តបានទេ ។

***ទីពីរ*** ក្នុងករណីរំលោភលើសេចក្តីទុកចិត្ត ជនជាប់ចោទត្រូវមានចេតនាកែបន្លំទ្រព្យសម្បត្តិពីម្ចាស់ ហើយម្ចាស់ទ្រព្យសម្បត្តិ មិនអាចទទួលបានទ្រព្យសម្បត្តិមកវិញរហូត ។ ការទាមទារនេះមានបំណងការពារមិនឱ្យសំណាងអាក្រក់ ក្លាយជាបទល្មើសព្រហ្មទណ្ឌ ។ នៅក្នុងឧទាហរណ៍ខាងលើអំពីការខ្ចីលុយដើម្បីដាំពោត **ម៉ូនីន** មិនមានលទ្ធភាពសងបំណុល ដោយសារភាពរាំងស្ងួតបំផ្លាញពោតរបស់គាត់ ។ នេះមិនមែនជាចេតនារបស់ **ម៉ូនីន**ទេ ។ អ្នកជិតខាង គាត់អាចប្តឹងគាត់ពីបទ រដ្ឋប្បវេណីស្តីពីការរំលោភលើកិច្ចសន្យា ។ ប៉ុន្តែ **ម៉ូនីន** មិនបានប្រព្រឹត្តិបទល្មើសការរំលោភលើសេចក្តីទុកចិត្តទេ ព្រោះគាត់គ្មានចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។

## ការអនុវត្តជាក់ស្តែងនៃការរំលោភលើសេចក្តីទុកចិត្តក្នុងពេលបច្ចុប្បន្ន

ដោយសារការទុកចិត្តប្រគល់ទ្រព្យសម្បត្តិ និងចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាធាតុផ្សំចាំបាច់ពីរនៃការរំលោភលើសេចក្តីទុកចិត្ត ការរំលោភលើកិច្ចសន្យាភាគច្រើនមិនអាចត្រូវគេចោទពីបទរំលោភលើសេចក្តីទុកចិត្តបានទេ ។ ក៏ប៉ុន្តែនៅប្រទេសកម្ពុជា គេធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌការរំលោភលើសេចក្តីទុកចិត្ត តាមរបៀបជាច្រើនដែលផ្ទុយពីច្បាប់ ។ អាជីវករបានរាយការណ៍ថា តុលាការមិនខ្វល់អំពីធាតុផ្សំចាំបាច់ ការទុកចិត្តប្រគល់

ទ្រព្យសម្បត្តិ និងចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទេ ហើយជួនកាលចាត់ទុកការរំលោភលើកិច្ចសន្យា ថាជាបទល្មើសរំលោភលើសេចក្ដីទុកចិត្ត ។

តាមរយៈ *របាយការណ៍ការធ្វើអាជីវកម្ម* ក្នុងប្រទេសកម្ពុជា គេប្រើពេលជាមធ្យម ៤០១ ថ្ងៃ និងត្រូវចំណាយ ១២៣ % នៃទឹកប្រាក់ជំលោះ ដើម្បីអនុវត្តកិច្ចសន្យាតាមរយៈបណ្ដឹងរដ្ឋប្បវេណីក្នុងប្រព័ន្ធតុលាការ ។[៣] ដោយសារការរំលោភលើសេចក្ដីទុកចិត្ត គឺជាបទល្មើសព្រហ្មទណ្ឌ គេអាចឃុំខ្លួនជនជាប់ចោទមុនការជំនុំជំរះក្ដីរយៈពេលជាច្រើនថ្ងៃ សប្ដាហ៍ ឬខែ មុនពេលគេធ្វើការចោទប្រកាន់ជាផ្លូវការ ។ ការឃុំខ្លួនមុនការជំនុំជំរះក្ដី បានដាក់សម្ពាធយ៉ាងខ្លាំងទៅលើជនជាប់ចោទ ឱ្យធ្វើអ្វីទាំងអស់រួមទាំងការបង់ប្រាក់ ដើម្បីអាចរួចផុតពីការឃុំខ្លួននេះបាន ។ គេអាចរួចពីការឃុំខ្លួនដោយបង់ប្រាក់ធានាខ្លួន ។ គេមានឱកាសតិចតួចណាស់ក្នុងការទទួលបានប្រាក់ធានាខ្លួនមកវិញ ។

*នៅប្រទេសកម្ពុជា ក្នុងករណីជាច្រើនគេប្រើប្រាស់ខុសមាត្រាស្ដីពីការរំលោភលើសេចក្ដីទុកចិត្ត ដើម្បីកែប្រែអ្វីដែលគួជារឿងក្ដីរដ្ឋប្បវេណី ឱ្យទៅជារឿងក្ដីព្រហ្មទណ្ឌ ព្រោះតុលាការមិនបានធ្វើការបែងចែកករណីទាំងពីរនេះទេ ។ បើបុគ្គលណាមួយចង់បង្ខំឱ្យបុគ្គលមួយទៀតដោះស្រាយបញ្ហា នោះគេចូលចិត្តប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្ត ។ នេះប្រហែលជាមកពីគេបកស្រាយខុសនូវមាត្រាទី ៤៦ ស្ដីពីការរំលោភលើសេចក្ដីទុកចិត្តនៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។*

**លោក Bretton G. Sciaroni**

**សហប្រធាន ក្រុមការងារស្ដីពីច្បាប់ ពន្ធដារ និងអភិបាលកិច្ចល្អ នៃវេទិកាផ្នែកឯកជនរបស់រាជរដ្ឋាភិបាល**

*ក្នុងការធ្វើអាជីវកម្មនៅប្រទេសកម្ពុជា មានករណីមិនសងប្រាក់ដែលជំពាក់ជាច្រើន ។ ការទាមទារលុយមកវិញ ដោយប្ដឹងតុលាការឱ្យអនុវត្តកិច្ចសន្យាប្រើពេលវេលាយូរណាស់ ។ បើគេប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្តវិញ ម្ចាស់បំណុលអាចទទួលបានប្រាក់លឿនជាងបណ្ដឹងរដ្ឋប្បវេណី ព្រោះការប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្តអាចឱ្យគេ ឃុំខ្លួនជនជាប់ចោទបាន ។ នេះជាវិធីទាលុយពីកូនបំណុល ។ តាមមាត្រា ទី ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បទរំលោភលើសេចក្ដីទុកចិត្តមានធាតុផ្សំគ្រប់គ្រាន់តាមផ្លូវច្បាប់ ។ ប៉ុន្តែមានការបកស្រាយមាត្រានេះខុស ដែលនាំឱ្យមានការអនុវត្តខុសអំពីបទរំលោភលើសេចក្ដីទុកចិត្ត ។*

**លោក ហែម ណារិទ្ធ កម្មសិទ្ធករ ក្រុមហ៊ុន B.N.G Co Ltd**

*ខ្ញុំមិនដែលជួបប្រទះរឿងក្ដីការរំលោភលើសេចក្ដីទុកចិត្តទេ ប៉ុន្តែខ្ញុំបានដឹងរឿងនេះពីមេធាវីមួយចំនួនដែលមាន អតិថិជន ត្រូវគេប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្ត ។ នៅប្រទេសកម្ពុជា គេប្រើប្រាស់ការរំលោភលើសេចក្ដីទុកចិត្ត ក្នុងផ្លូវខុស ។ គេបានកែប្រែបណ្ដឹងរដ្ឋប្បវេណីខ្លះ ឱ្យទៅជាបទព្រហ្មទណ្ឌស្ដីពីការរំលោភលើសេចក្ដីទុកចិត្ត ព្រោះចៅក្រមខ្លះមិនយល់ច្បាស់ពីបញ្ហានេះ ។ រីឯម្ចាស់បំណុលខ្លះចូលចិត្តប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្ត ព្រោះវាជាបទព្រហ្មទណ្ឌ ហើយដោយសារ កូនបំណុលខ្លាចការឃុំខ្លួនមុនការជំនុំជំរះក្ដី និងធ្វើអ្វីៗទាំងអស់ដើម្បីបង់ប្រាក់ទៅឱ្យម្ចាស់បំណុលដើម្បី ជៀសឱ្យផុតពីការឃុំខ្លួន ទោះជាត្រូវខ្ចីប្រាក់ពីអ្នកដទៃទៀត ឬកលក់ទ្រព្យសម្បត្តិរបស់ខ្លួនក៏ដោយ ។*

**លោក កុយ នាម មេធាវី**

*ក្នុងការធ្វើអាជីវកម្ម តែងតែមានជំលោះ ។ ឧទាហរណ៍ បុគ្គលពីរនាក់រកស៊ីចូលហ៊ុនគ្នា ។ ពេលដែលការរកស៊ីនេះខាតបង់ ភាគីម្ខាងទាមទារលុយមកវិញ ។ ករណីនេះកើតឡើងជាញឹកញាប់ ក្នុងការធ្វើអាជីកម្មនៅកម្ពុជា ។ បើសិនជាភាគី នោះប្ដឹងពីបទរដ្ឋប្បវេណី គឺប្រើពេលយូរហើយពេលខ្លះមិនអាចទទួលលុយមកវិញ ។ មានមធ្យោបាយមួយដើម្បីឱ្យគេទាលុយនោះមកវិញបាន គឺប្ដឹងដៃគូរកស៊ីពីបទរំលោភលើសេចក្ដីទុកចិត្ត ។ ក្នុងករណីជាច្រើននៃការប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្តជនជាប់ចោទត្រូវបានគេឃុំខ្លួនជាបណ្ដោះអាសន្ន ។ ជនជាប់ចោទត្រូវបង់ប្រាក់ ធានាខ្លួនដើម្បីអាចរួចពីការឃុំខ្លួន ។ ជាទូទៅប្រាក់ធានាមានតំលៃស្មើនឹងទឹកប្រាក់នៃជំលោះ ។ តាមការពិត ជំលោះរបៀបនេះជាជំលោះរដ្ឋប្បវេណី ។ ក៏ប៉ុន្តែ តុលាការកែប្រែវាឱ្យទៅជាជំលោះព្រហ្មទណ្ឌ ដើម្បីទារលុយ ពីជនជាប់ចោទ ។*

**លោក គង់ ពីសី ប្រធានបច្ចេកទេសមេធាវី ក្រុមអ្នកការពារសិទ្ធកម្ពុជា**

## ឥទ្ធិពលនៃរឿងក្ដីរំលោភលើសេចក្ដីទុកចិត្តទៅលើសេដ្ឋកិច្ចកម្ពុជា

ការរំលោភលើសេចក្ដីទុកចិត្តជាការបារម្ភចំបងមួយក្នុងសហគមន៍អាជីវកម្ម ព្រោះគេប្រើប្រាស់វាមិនបានត្រឹមត្រូវក្នុងរឿងក្ដីមួយចំនួន ។ ការប្រើប្រាស់ការរំលោភលើសេចក្ដីទុកចិត្តដោយបំពានដើម្បីដោះស្រាយជំលោះអាជីវកម្ម ជះឥទ្ធិពលដល់សេដ្ឋកិច្ចកម្ពុជាតាមពីររបៀបផ្សេងគ្នា៖ *ទីមួយ* ជនជាប់ចោទខាតបង់ដោយផ្ទាល់ទៅលើការចំណាយដែលទាក់ទងនឹងច្បាប់ ហើយសេដ្ឋកិច្ចកម្ពុជាខាតបង់ដោយប្រយោល ដោយសារការបាត់បង់ឱកាសវិនិយោគ ។

ទោះបីជាការសិក្សារនេះអាចមិនតំណាងឱ្យប្រទេសទាំងមូល គេប៉ាន់ស្មានថាជនជាប់ចោទខាតបង់ដោយផ្ទាល់ ពីរាប់ពាន់ ទៅរាប់ម៉ឺនដុល្លារក្នុងមួយរឿងក្ដីដែលគេចោទដោយបំពានពីបទរំលោភលើសេចក្ដីទុកចិត្ត ។ ការចំណាយនោះ រួមមាន ការចំណាយលើមេធាវី និងប្រាក់សំណូកដែលពាក់ព័ន្ធនឹងបណ្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្ត ។ ការខាតបង់មួយទៀត គឺការបាត់បង់ពេលវេលាដែលស្ថិតក្នុងការឃុំឃាំង ដែលធ្វើឱ្យជននោះមិនអាចធ្វើការ ឬរកប្រាក់បាន ។

ឥទ្ធិពលដោយប្រយោលនៃការរំលោភលើសេចក្ដីទុកចិត្ត គឺការបាត់បង់ឱកាសវិនិយោគ ។ ដោយសារតែខ្លាច គេប្ដឹងពីបទរំលោភលើសេចក្ដីទុកចិត្ត អាជីវករកាត់បន្ថយឱកាសវិនិយោគ ។ បើសិនជាគ្មានករណីនេះទេ គេអាចបង្កើតជំនួញដែលអាចផ្ដល់ប្រាក់ចំណេញបាន ។ ការប៉ាន់ស្មានដំបូងដែលផ្អែកលើការអង្កេត និងការសម្ភាសន៍ បង្ហាញថា សេដ្ឋកិច្ចកម្ពុជាបាត់បង់ឱកាសវិនិយោគលើសពី ៥ លានដុល្លារក្នុងមួយឆ្នាំៗ ។

*ក្នុងប្រទេសកម្ពុជា ការប្រើប្រាស់ការរំលោភលើសេចក្ដីទុកចិត្តដោយបំពាន មានឥទ្ធិពលជាអវិជ្ជមានមកលើ អាជីវកម្ម ។ វាមិនលើកទឹកចិត្តអាជីវករឱ្យមកវិនិយោគនៅកម្ពុជាទេ ។ ជំលោះអាជីវកម្មអាចកើតឡើងគ្រប់ទីកន្លែង លើពិភពលោក ប៉ុន្តែគេចាត់ទុកវាជាបទល្មើសរដ្ឋប្បវេណី ។ ពេលដែលអ្នកវិនិយោគដឹងថា ជំលោះអាជីវកម្ម អាចមានទោសព្រហ្មទណ្ឌ*

[៣] សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងធនាគារពិភពលោក *ការធ្វើអាជីវកម្ម ឆ្នាំ ២០០៧: របៀបធ្វើកំណែទំរង់* វ៉ាស៊ីនតោន ឌី ស៊ី ខែកញ្ញា ឆ្នាំ ២០០៦

*អ្នកវិនិយោគនឹងមិនមកវិនិយោគទេ ព្រោះគេត្រូវប្រថុយនឹងការឃុំខ្លួនក្នុងពន្ធនាគារ ។ ជាលទ្ធផល ប្រទេសកម្ពុជា នឹងខាតបង់ ដោយសារអ្នកវិនិយោគកាត់បន្ថយឱកាសវិនិយោគ ។*

លោក Bretton G. Sciaroni

**សហប្រធាន ក្រុមការងារស្តីពីច្បាប់ ពន្ធដារ និងអភិបាលកិច្ចល្អ នៃវេទិកាផ្នែកឯកជនរបស់រាជរដ្ឋាភិបាល**

*បើគេប្តឹងធនាគារិកមួយពីបទរំលោភលើសេចក្តីទុកចិត្ត ដោយសារតែជំលោះកិច្ចសន្យាអាជីវកម្មធម្មតា ហើយត្រូវគេឃុំខ្លួនព្រោះជំលោះនេះ វានឹងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ ។ ជាលទ្ធផល អតិថិជននឹងបាត់បង់ទំនុកចិត្តលើធនាគារនោះ ហើយធនាគារនឹងបាត់បង់អតិថិជន ជាពិសេសអ្នកផ្ញើរប្រាក់នៅធនាគារ ។*

**លោក ព្រំ វិសុទ្ធ ប្រធាន នាយកដ្ឋាននិតិកម្ម ធនាគារ អេស៊ីលីដា ភីអិលស៊ី**

*ក្នុងអាជីវកម្ម ការខ្ចីប្រាក់សំរាប់ធ្វើអាជីវកម្មសំខាន់ណាស់ ព្រោះវារួមចំណែកពង្រីកអាជីវកម្ម និងបង្កើតប្រាក់ចំណេញ ។ ក៏ប៉ុន្តែ បើការមិនសងប្រាក់ដោយសារក្ស័យធនអាចនាំឱ្យគេឃុំខ្លួន វានឹងបង្អាក់អាជីវករមិនឱ្យខ្ចីលុយ ។ ទីបំផុត វានឹងធ្វើឱ្យអាជីវកម្មរីកចំរើនយឺត ។*

**លោក កុយ នាម មេធាវី**

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

រឿងក្តីរំលោភលើសេចក្តីទុកចិត្តមួយចំនួនតូច តែមានសារៈសំខាន់ត្រូវបានគេប្តឹងដោយមិនត្រឹមត្រូវ ហើយគេអនុវត្តមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្តដោយមិនត្រឹមត្រូវ ។ តុលាការមិនខ្វល់ពីធាតុផ្សំ របស់ការរំលោភលើសេចក្តីទុកចិត្តទេ ហើយកែប្រែការរំលោភលើកាតព្វកិច្ច កិច្ចសន្យាឱ្យទៅជាការរំលោភ លើសេចក្តីទុកចិត្ត ដើម្បីឱ្យមន្ត្រីតុលាការ និងនគរបាលអាចទទួលបានសំណូកពីជនជាប់ចោទ ។

ការអនុវត្តការរំលោភលើសេចក្តីទុកចិត្តមិនត្រឹមត្រូវ និងមិនយុត្តិធម៌ មានឥទ្ធិពលជាអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ។ សេដ្ឋកិច្ចកម្ពុជាបាត់បង់រាប់លានដុល្លារជារៀងរាល់ឆ្នាំ ដោយសារការអនុវត្តដោយមិនត្រឹមត្រូវនូវមាត្រាស្តីពីការរំលោភលើសេចក្តី ទុកចិត្ត ។ បើគេប្រើលុយទាំងនេះក្នុងផលិតកម្មវិញ នោះវាអាច បង្កើតការងាររាប់ពាន់សំរាប់ប្រជាជនកម្ពុជា ។

អនុសាសន៍ខាងក្រោម អាចជួយទប់ស្កាត់ការរំលោភលើច្បាប់ព្រហ្មទណ្ឌអន្តរកាលស្តីពីការរំលោភលើសេចក្តីទុកចិត្ត ។ ជាលទ្ធផល វាអាចជួយមិនឱ្យអ្នកវិនិយោគភ័យព្រួយ និងលើកទឹកចិត្តពួកគេឱ្យវិនិយោគ ដើម្បីបង្កើតការងារ ។

*ផ្តោតលើធាតុផ្សំនៃការទុកចិត្តប្រគល់អ្វីមួយឱ្យអ្នកដទៃទទួលខុសត្រូវ និងចេតនានៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ*

រឿងក្តីការរំលោភលើសេចក្តីទុកចិត្តជាច្រើនអាចលុបចោលបាន បើគេផ្តោតលើភស្តុតាងនៃការទុកចិត្ត ប្រគល់អ្វីមួយឱ្យអ្នកដទៃទទួលខុសត្រូវ និងចេតនានៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ គេគួរតែចេញសេចក្តីណែនាំមួយ ដែលទាមទារធាតុផ្សំទាំងពីរខាងលើនៅពេលដែលតុលាការចេញសាលក្រមអំពី ការរំលោភលើសេចក្តីទុកចិត្ត ។

*បោះពុម្ពផ្សាយសេចក្តីសំរេចទាំងអស់នៃរឿងក្តីអំពីការរំលោភលើសេចក្តីទុកចិត្ត*

ការដែលគេមិនអាចមានសាលក្រមរបស់តុលាការក្នុងប្រទេសកម្ពុជា ធ្វើឱ្យគេពិបាកត្រួតពិនិត្យថា តើអង្គហេតុបានផ្អែកលើភស្តុតាងគ្រប់គ្រាន់សំរាប់ធាតុផ្សំនីមួយៗនៃបទល្មើសព្រហ្មទណ្ឌឬទេ ។ ក្រោយពេលដែលតុលាការចេញសាលក្រម គេគួរតែបោះផ្សាយមតិលើការរំលោភលើសេចក្តីទុកចិត្ត ។ ការបោះពុម្ព ផ្សាយនេះនឹងជួយឱ្យគេតាមដានភស្តុតាងនានាដែលនាំឱ្យមានសេចក្តីសំរេចនោះ ហើយអាចជួយឱ្យគេផ្តោតទៅលើធាតុផ្សំសំខាន់ៗនៃការរំលោភលើសេចក្តីទុកចិត្តផងដែរ ។

*ដំណោះស្រាយដែលល្អគឺ ត្រូវអនុម័តសេចក្តីព្រាងច្បាប់ក្រមព្រហ្មទណ្ឌថ្មី ហើយធានាថាគេសរសេរច្បាប់នេះដោយប្រុងប្រយ័តជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ដំណោះស្រាយរយៈពេលខ្លីគឺ បោះផ្សាយសាលក្រមរបស់តុលាការ លើរឿងក្តីរំលោភលើសេចក្តីទុកចិត្ត ដើម្បីឱ្យសាធារណៈជនអាចមើលឃើញការអនុវត្តរបស់តុលាការ ។ នេះអាចធ្វើឱ្យមេធាវី ឬព្រះរាជអាជ្ញាប្រុងប្រយ័ត្ន ក្នុងការលើកបញ្ហានេះឡើង ។ ក្នុងពេលបច្ចុប្បន្ននេះ សាលក្រមរបស់តុលាការមិនប្រកាសឱ្យគេដឹងទូលំទូលាយទេ ។ បើមនុស្សគ្រប់គ្នាមានសាលក្រមរបស់តុលាការ គេអាចយកវាទៅធ្វើការវិភាគ ។ នេះអាច ធ្វើឱ្យតុលាការមានការប្រុងប្រយ័ត្ន ។*

លោក Bretton G. Sciaroni

**សហប្រធាន ក្រុមការងារស្តីពីច្បាប់ ពន្ធដារ និងអភិបាលកិច្ចល្អ នៃវេទិកាផ្នែកឯកជនរបស់រាជរដ្ឋាភិបាល**

*បង្កើតយន្តការសំរាប់ឱ្យរាយការណ៍ជាអនាមិក ពីបុគ្គលិកតុលាការ ឬនគរបាលណាដែលទារសំណូក*

ការរាយការណ៍ជាអនាមិក អាចជួយឱ្យគេតាមដាន ក្រឡាបញ្ជី ចៅក្រម ព្រះរាជាអាជ្ញា និងនគរបាល ដែលដាក់សម្ពាធលើជនជាប់ចោទដើម្បីបានសំណូក ។ ក្រឡាបញ្ជី ចៅក្រម ព្រះរាជាអជ្ញា និងនគរបាលប្រហែលជា មិនហ៊ានទាសំណូកទេ បើគេដឹងថាជនជាប់ចោទអាចរាយការណ៍រឿងនេះទៅអ្នកណាម្នាក់ដែលអាចសើបអង្កេតរឿងនេះបាន ។ ការរាយការណ៍ជាអនាមិកអាចជួយជំរុញឱ្យមានការរាយការណ៍រឿងក្តីដែលចោទប្រកាន់ដោយបំពានអំពីការរំលោភលើសេចក្តីទុកចិត្ត ព្រោះគេយល់ថាមានសុវត្ថភាពក្នុងការ រាយការណ៍ ។

*ដាក់កំហិតការឃុំខ្លួនមុនការជំនុំជំរះក្តី ដោយចេញសេចក្តីណែនាំ ការងារជាផ្លូវការមួយ ដែលពិពណ៌នាយ៉ាងច្បាស់ថាពេលណាត្រូវប្រើការឃុំខ្លួនមុនការជំនុំជំរះ*

ដូចដែលបានបង្ហាញរួចហើយថា ជួនកាលគេប្រើការឃុំខ្លួនមុនការជំនុំជំរះក្តីដើម្បីធ្វើជាការគំរាមកំហែងដើម្បីទាសំណូកពីជនជាប់ចោទ ។ ដូច្នេះគេគួរដាក់កំហិតវា ដោយចេញសេចក្តីណែនាំឱ្យច្បាស់សំរាប់តុលាការថា កត្តាអ្វីខ្លះដែលអាចកំណត់ថាជនជាប់ចោទអាចនឹងរត់គេចខ្លួន ។ គេគួរតែបរិយាយឱ្យ បានច្បាស់ថាពេលណាដែលជាការសមស្រប ក្នុងការបង់ប្រាក់ធានាខ្លួន ហើយបរិយាយពីរបៀបគណនាប្រាក់ធានាខ្លួន និងយន្តការដែលអាចឱ្យគេយកប្រាក់ធានាខ្លួនមកវិញបាន ។


រក្សាសិទ្ធិ MPDF 2006
Publisher: MPDF No. 70, Norodom Blvd., Phnom Penh
Tel: (855)-23-210-922 Fax: (855)-23-215-157
E-mail: shor@ifc.org Website: www.mpdf.org
Layout by: Kea Kunthea
Printed by: MAKARA Printing House